**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

*ថ្ងៃពុធ ១៣រោច ខែផល្គុន ឆ្នាំឆ្លូវ ត្រីស័ក ព.ស. ២៥៦៥*

*រាជធានីភ្នំពេញ ថ្ងៃទី៣០ ខែមីនា ឆ្នាំ ២០២២*

# សេចក្តីប្រកាសព័ត៌មាន

## កិច្ចប្រជុំគណៈកម្មាធិការសម្របសម្រួលអន្តរក្រសួងរៀបចំផែនការមេ ដើម្បីអភិវឌ្ឍខេត្តព្រះសីហនុទៅជាតំបន់សេដ្ឋកិច្ចពិសេសគំរូពហុបំណង

## ស្តីពី

## “សេចក្តីព្រាងរបាយការណ៍លទ្ធផលសម្រាប់ដំណាក់កាលទី ១ នៃការរៀបចំផែនការមេ ដើម្បីអភិវឌ្ឍខេត្តព្រះសីហនុទៅជាតំបន់សេដ្ឋកិច្ចពិសេសគំរូពហុបំណង”

នាព្រឹកថ្ងៃទី ៣០ ខែមីនា ឆ្នាំ ២០២២, ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ **អូន ព័ន្ធមុនីរ័ត្ន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងជាប្រធានគណៈកម្មាធិការសម្របសម្រួលអន្តរក្រសួងរៀបចំផែនការមេ ដើម្បីអភិវឌ្ឍខេត្តព្រះសីហនុទៅជាតំបន់សេដ្ឋកិច្ចពិសេសគំរូពហុបំណង (**គ.ស.ផ.**) បានដឹកនាំកិច្ចប្រជុំ ដើម្បីពិនិត្យ និងពិភាក្សាលើ “**សេចក្តីព្រាងរបាយការណ៍លទ្ធផលសម្រាប់ដំណាក់កាលទី ១ នៃការរៀបចំផែនការមេ ដើម្បីអភិវឌ្ឍខេត្តព្រះសីហនុទៅជាតំបន់សេដ្ឋកិច្ចពិសេសគំរូពហុបំណង**” តាមរយៈប្រព័ន្ធអនឡាញ ដោយមានការអញ្ជើញចូលរួមពីឯកឧត្តម លោកជំទាវ ជាថ្នាក់ដឹកនាំជាន់ខ្ពស់នៃក្រសួង-ស្ថាប័នពាក់ព័ន្ធជាសមាជិក-សមាជិការ នៃ **គ.ស.ផ.** ។

គោរពតាមគោលការណ៍ឯកភាពដ៏ខ្ពង់ខ្ពស់បំផុតរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា**, ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បានជ្រើសរើសយក **វិទ្យាស្ថាននគរូបនីយកម្ម និងឌីសាញស៊ិនជិន (Urban Planning and Design Institute of Shenzhen)** ហៅកាត់ថា UPDIS ដើម្បីផ្តល់សេវាកម្មក្នុងការរៀបចំផែនការមេដ៏មានសារៈសំខាន់នេះ ដែលត្រូវបានចែកជា ៥ ដំណាក់កាល ដោយត្រូវចំណាយពេលប្រមាណ ១៨ ខែ ។ វិទ្យាស្ថាន UPDIS គឺជាស្ថាប័នរៀបចំនគរូបនីយកម្ម ដែលមានបទពិសោធន៍ច្រើន និងទូលំទូលាយ ក្នុងការរៀបចំផែនការមេ, ទាំងនៅក្នុងប្រទេសចិន និងលើសកលលោកទាំងមូល, និងជាស្ថាប័ននាំមុខក្នុងការរៀបចំផែនការមេអភិវឌ្ឍន៍ទីក្រុងស៊ិនជិន ដែលជាមជ្ឈមណ្ឌលពាណិជ្ជកម្ម និងបច្ចេកវិទ្យាដ៏ល្បីល្បាញក្នុងប្រទេសចិន ។

វិទ្យាស្ថាន UPDIS បានរៀបចំ "**សេចក្តីព្រាងរបាយការណ៍លទ្ធផលសម្រាប់ដំណាក់កាលទី ១ នៃការរៀបចំផែនការមេ ដើម្បីអភិវឌ្ឍខេត្តព្រះសីហនុទៅជាតំបន់សេដ្ឋកិច្ចពិសេសគំរូពហុបំណង**" ដោយផ្តោតលើផ្នែកសំខាន់ៗចំនួន ២ រួមមាន ១.ការវិភាគតំបន់ និងស្ថានភាព និង ២.ទស្សនាទានបឋមដែលបង្ហាញពីរូបភាពអនាគតនៃការរៀបចំផែនការមេ ។ ជារួម, សេចក្តីព្រាងរបាយការណ៍នេះគឺជាទស្សនាទានបឋមនៃផែនការមេអភិវឌ្ឍខេត្តព្រះសីហនុ ក្នុងកម្រិតម៉ាក្រូ ដែលមានចរិកជាយុទ្ធសាស្ត្រ និងទិសដៅគោលនយោបាយ ។

ការរៀបចំផែនការមេនេះ គឺជាផ្នែកមួយនៃការគិតគូរជាយុទ្ធសាស្ត្រ ក្នុងរយៈពេលមធ្យម និងវែងរបស់រាជរដ្ឋាភិបាលកម្ពុជា ដើម្បីប្រែក្លាយខេត្តព្រះសីហនុឱ្យទៅជាតំបន់សេដ្ឋកិច្ចគំរូពហុបំណង និងជាប៉ូលសេដ្ឋកិច្ចដ៏សំខាន់មួយសម្រាប់ជំរុញកិច្ចអភិវឌ្ឍជាតិឱ្យរីកចម្រើនទៅមុខ ប្រកបដោយចីរភាព និងបរិយាប័ន្ន ស្របតាមការកំណត់ក្នុងគោលនយោបាយអភិវឌ្ឍវិស័យឧស្សាហកម្មកម្ពុជា ២០១៥-២០២៥ ។ ការរៀបចំផែនការមេនេះគឺមានការគិតគូរយ៉ាងល្អិតល្អន់ ដោយរៀបចំឱ្យមានហេដ្ឋារចនាសម្ព័ន្ធទំនើប ប្រកបដោយនវានុវត្តន៍ខ្ពស់ ដែលអាចចាត់ទុកជាប្រភេទទីក្រុងវៃឆ្លាត (SMART CITY) ទាំងការរៀបចំសំណង់អគារ, តំបន់លំនៅដ្ឋាន, ការកំណត់តំបន់ឧស្សាហកម្ម, តំបន់ការពារបរិស្ថាន ។ល។ ប្រកបដោយការច្នៃប្រឌិតខ្ពស់ សោភ័ណ្ឌភាព និងផាសុខភាពដែលគួរឱ្យចង់រស់នៅ ។

អង្គប្រជុំបានពិនិត្យ ពិភាក្សា និងសម្រេចលើខ្លឹមសារសំខាន់ៗនៃសេចក្តីព្រាងរបាយការណ៍នេះ ព្រមទាំងបានផ្តល់អនុសាសន៍គន្លឹះ ពិសេស ផ្តោតលើទិសដៅអភិវឌ្ឍ, វិស័យសេដ្ឋកិច្ច-ឧស្សាហកម្មដែលមានសក្តានុពល, ការរៀបចំប្លង់គោល និងក្របខ័ណ្ឌស្ថាប័ន ជាដើម ដើម្បីជួយតម្រង់ទិសឱ្យក្រុមការងារនៃវិទ្យាស្ថាន UPDIS កែតម្រូវសេចក្តីព្រាងរបាយការណ៍ដំណាក់កាលទី ១ នេះ ឱ្យមានលក្ខណៈគ្រប់ជ្រុងជ្រោយ សម្រាប់ជាត្រីវិស័យដើម្បីជាមូលដ្ឋានក្នុងការសិក្សា និងរៀបចំការងារជំហានបន្តបន្ទាប់ទៀត ។

ជាកិច្ចបញ្ចប់, ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ **អូន ព័ន្ធមុនីរ័ត្ន** ឧបនាយករដ្ឋមន្ត្រី ប្រធានអង្គប្រជុំ បានថ្លែងអំណរគុណ និងវាយតម្លៃខ្ពស់ចំពោះការចូលរួមគាំទ្រ និងផ្តល់កិច្ចសហការពីថ្នាក់ដឹកនាំគ្រប់ក្រសួង-ស្ថាប័នពាក់ព័ន្ធ ជាពិសេសក្រុមការងារដឹកនាំដោយវិទ្យាស្ថាន UPDIS ដែលបានខិតខំរៀបចំសេចក្តីព្រាងរបាយការណ៍លទ្ធផល ក្នុងដំណាក់កាលទី ១ និងបានណែនាំឱ្យក្រុមការងារធ្វើការកែសម្រួលឯកសារនេះ ស្របតាមស្មារតីនៃកិច្ចប្រជុំ ដើម្បីជាមូលដ្ឋានសម្រាប់កិច្ចការ ក្នុងដំណាក់កាលទី ២ នៃការរៀបចំផែនការមេ ដើម្បីអភិវឌ្ឍខេត្តព្រះសីហនុទៅជាតំបន់សេដ្ឋកិច្ចពិសេសគំរូពហុបំណង ៕